**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៦៦
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១
**<u>សាលដីកា</u>**
លេខ:១១៦
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រមរបាយការណ៍
៣-លោក ............. ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក ............

**<u>តំណាងមហាអយ្យការ</u>**

-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៤៩(ឈ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៩៣ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះថស លីឡាប្រាក់ថាក់ (Tongst leapratak) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិថៃ មុខរបរ តំណាងឱ្យក្រុមហ៊ុនពិតពាណិជ្ជា ទីលំនៅ ផ្ទះលេខ៣៣ វិថីសម្តេចចក្រីប៉ុន ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវី លោកស្រី ............

និងចុងបណ្តឹងសាទុក្ខឈ្មោះវេសអភេទប្រុសអាយុ៤៥ឆ្នាជាតិខ្មែរ មុខរបរពាណិជ្ជករទីលំនៅផ្ទះលេខ៩០ ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង ខណ្ឌចំការមន ក្រុងភ្នំពេញ។

មានមេធាវី លោក ...............

**<u>អំពីវិវាទ</u>** សុំប្តឹងមោឃៈភាពកិច្ចសន្យា

បានឃើញបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី២២ ខែមករាឆ្នាំ២០០១ របស់លោកស្រី............ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៤៩(ឈ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៦៦ ចុះថ្ងៃទី២៨ ខែកុម្ភៈឆ្នាំ២០០១ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៨-៥-១៩៩៨ របស់ដើមចោទលោក ...............ប្ដឹងសុំមោឃៈភាពកិច្ចសន្យារវាងក្រុមហ៊ុនពិភពពាណិជ្ជកម្មជា និងខ្លួន និងទាមទារប្រាក់USD97500(កៅ សិបប្រាំពីរពាន់ប្រាំរយដុល្លាអាមេរិកគត់) ពីឈ្មោះថងសិទ្ធិ លីឡាប្រាក់ថាក់ (Tongsit leapratak) ជាប្រធានក្រុមហ៊ុនពិភពពាណិជ្ជកម្មជា និង ឈ្មោះ ឡៃគថ (Lai kim Tong) ជាប្រធានចាត់ការទូទៅ នៃក្រុមហ៊ុនពិភពពាណិជ្ជកម្មជា។ ការរកស៊ីរួមគ្នានេះ ដែលមានលោក ថងសិទ្ធិ លីឡាប្រាក់ថាក់ ហៅកាត់ថា ភាគី (ក) បានចុះកិច្ចសន្យារកស៊ីរួមគ្នាជាមួយខ្លួន ...............ហៅកាត់ថា ភាគី(ខ)

ភាគី(ខ) បានចេញដើមទុនដូចជា

១- បានប្រគល់ប្រាក់កក់ទៅឱ្យភាគី(ក) ចំនួន៦០០០០ ដុល្លាអាមេរិក គឺលើកទី១ ថ្ងៃទី៨-៦-១៩៩៧ចំនួន៣០០០០ដុល្លាអាមេរិក និងលើកទី២ ថ្ងៃទី២៥-៦-១៩៩៧ចំនួន៣០០០០ ដុល្លាអាមេរិក ។

២- បានឱ្យប្រាក់ថ្លៃជួសជុលទៅភាគី (ក)ពីរលើកចំនួន១២៥០០ ដុល្លាអាមេរិកគឺៈ

- លើកទី១ ថ្ងៃទី២២-១០-៩៧ ចំនួន ៨០០០ដុល្លាអាមេរិក

- លើកទី២ ថ្ងៃទី០៨-១២-៩៧ ចំនួន៤៥០០ដុល្លាអាមេរិក

៣- ដើម្បីឱ្យភាគី (ខ) នាំគ្រឿងចក្រចូលក្នុងទីតាំងធ្វើអាជីវកម្ម បានភាគី(ក) ឱ្យភាគី (ខ) ជួសជុលកែលំអកាមតម្រូវការអស់ប្រាក់ចំនួន២០០០០ ដុល្លាអាមេរិក ។

៤- ភាគី(ក)បានឱ្យភាគី(ខ) ចេញថ្លៃឈ្នួលទីតាំងសំរាប់ខែវិច្ឆិកាឆ្នាំ១៩៩៧ ក្នុង១ខែចំនួន ៥០០០ ដុល្លាអាមេរិក ។

សរុបទាំងអស់ចំនួន៩៧៥០០ដុល្លាអាមេរិក

រាល់ការប្រគល់ទៅឱ្យភាគី(ក) គឺលោក ឡៃគថ ជាប្រធានចាត់ការទូទៅ នៃក្រុមហ៊ុនពិភពពាណិជ្ជកម្មជាជាអ្នកទទួល ។

តាមពាក្យបណ្ដឹងតប ចុះថ្ងៃទី២៨ ខែកក្កដាឆ្នាំ១៩៩៨ របស់អ្នកស្រី............ជាមេធាវីតំណាងឱ្យឈ្មោះថស លីឡាប្រាក់ថាក់ ដែលជាតំណាងក្រុមហ៊ុនពិភពពាណិជ្ជបានចុះកិច្ចសន្យា ជួលរោងចក្រតម្បាញទី២ ពីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល(ចុះថ្ងៃទី១២-១០-៩៣) ហើយ ក្រសួងនេះបានចេញប្រកាសប្រគល់សិទ្ធិ និងការគ្រប់គ្រងផលិតកម្មអាជីវកម្ម លើរោងចក្រតម្បាញទី២ នេះ ជូនក្រុមហ៊ុន ថ្ងៃទី០២-១១-៩៣ ។ បន្ទាប់មកក្រុមហ៊ុននេះ ដែលមានលោកថស លីឡាប្រាក់ថាក់ ជាតំណាងបានចុះកិច្ចសន្យាសហប្រតិបត្តិការរួមមួយ (Joint venture Agreement) ជាមួយលោក...............គឺទាក់ទង និងខ្លឹមសារ នៃកិច្ចសន្យាសហប្រតិបត្តិការរួមនេះ នៅថ្ងៃទី០៨-៦-១៩៩៧ ជាភាសាអង់គ្លេស តែម្តង ដែលបង្កើតនូវវិវាទ ថ្ងៃនេះឡើង ។

បានឃើញ ដីកាសម្រេចតាមពាក្យសុំលេខ០៣(ឃ) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ..............ដែលមានតំណាង និងជាមេធាវីឈ្មោះ.............. ចុះថ្ងៃទី១៨-៥-១៩៩៨ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់ (TONGSTIT LELAPRATAK)និងឈ្មោះ (LAI KIM TONG) មិនឱ្យលក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំ ជួល ឬ ធ្វើអំណោយ នូវទីស្នាក់ក្រុមហ៊ុនផ្ទះលេខ៣១-៣៣ វិថីសម្តេច ចក្រីប៉ុន ផ្លូវលេខ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ព្រមទាំងចលនទ្រព្យ និងអចលនទ្រព្យ ដែលជាចំណែកភាគហ៊ុនរបស់ខ្លួនមាននៅក្នុងៈ

-ក្រុមហ៊ុន ពិភពពាណិជ្ជកម្ពុជា

-ក្រុមហ៊ុន ពិភពពាណិជ្ជធានារ៉ាប់រង

-រោងចក្រតម្បាញពិភពពាណិជ្ជ

-ក្រុមហ៊ុន ពិភពពាណិជ្ជកម្ពុជា ម៉ូធ័ចំកាត់

-ក្រុមហ៊ុន កម្ពុជាផ្សាយពាណិជ្ជកម្ម

-រោងចក្រកម្ពុជា ដេយេធឹងចំកាត់

-ក្រុមហ៊ុន K-N-Tទីផ្សារសុរាចំកាត់

-រថយន្តតូចធំ សំរាប់ជួល

ដែលមានអាស័យដ្ឋានផ្ទះលេខ៣១-៣៣ វិថីសម្តេចចក្រប៉ុន ផ្លូវលេខ២០៨ សង្កាត់ បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

រោងចក្រតម្បាញពិភពពាណិជ្ជភ្នំពេញ និងទ្រព្យសម្បត្តិទាំងអស់ ដែលមាននៅក្នុងរោង ចក្រនេះ ដែលមានទីតាំងនៅផ្លូវជាតិ៥ ភូមិឃ្លាំងសាំង សង្កាត់ឬស្សីកែវ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

រថយន្តជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ពិភពពាណិជ្ជកម្ពុជា ម៉ូធ័រចំកាត់គឺៈ

Fiat Panda 1.000 = 5 Units
Panda 4x4 = 5 Units
Uno Super 60 = 2 Units
Tipo SX = 2 Units

ទុកជាបណ្តោះអាសន្នសិន រង់ចំតុលាការសម្រេចដល់រឿងអង្គសេចក្តី ។

៣- បង្គាប់ឱ្យឈ្មោះ...............ដែលមានតំណាង និងជាមេធាវីឈ្មោះការ សាវុត្ត ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបបង់ប្រាក់២០០រៀល បូកសរុប ២០០០រៀល ប្រាក់នេះ បានកាត់យកពីប្រាក់២០០០រៀល ដោយដើមចោទបានបង់ទុកជាស្រេច ។

៤- បើគូភាគីណាមិនសុខចិត្តនឹងដីកាសម្រេចនេះ មានសិទ្ធិប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីដីកាសម្រេចនេះតទៅ ។

បានឃើញ ដីកាសម្រេចកិច្ចការប្រញាប់លេខ២៤ ប្រក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលសម្រេចៈ

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១០-៧-២០០១ របស់ឈ្មោះសដវ ទុកជាត្រឹម ត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសំណូមពរ គ្រប់ចំណុចរបស់លោក..............តំណាងដោយ លោកស្រីទិត សោភ័ណ ចោល ។

៣- សម្រេចដកចេញពី ដីកាសម្រេចតាមពាក្យសុំលេខ០៣(ឃ) ចុះថ្ងៃទី២៨-៥-១៩៩៨ របស់តុលាការក្រុងភ្នំពេញនូវផ្ទះលេខ៣១ ផ្លូវ ២០៨ ក្រុម៥ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឱ្យរួចផុតពីការហាមឃាត់ ។ ឯចលនទ្រព្យ និង អចលនទ្រព្យផ្សេងពីនេះ ទុកឱ្យស្ថិតនៅក្នុងការហាម ឃាត់នៃដីកាសម្រេចតាមពាក្យសុំលេខ០៣(ឃ) ចុះថ្ងៃទី ២៨-៥-១៩៩៨ ដដែល ។

៤- បង្គាប់ឱ្យដើមចោទ បង់ប្រាក់ប្រដាប់ក្តីចំនួន៥០០០រៀល ។ ប្រាក់នេះបានកាត់យកពី ប្រាក់ប្រដាប់ក្តីរបស់ដើមចោទ ដាក់ថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ ។

៥- ដីកានេះ សម្រេចសេចក្តី និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីលឹម ច័ន្ទប៉ុនកែវ តំណាងដើមចោទឈ្មោះសដវ ចំពោះមុខលោកស្រីទិត សោភ័ណ តំណាងឈ្មោះ..............បើក ផ្លូវប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ១២(ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ដែលមានអ្នកទទួលសិទ្ធិមេធាវីការ សាវុត្ត ចុះថ្ងៃទី១៨-៥-១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងតប របស់ចុងចម្លើយ ថងសិទ្ធិ លីឡាប្រាក់ថាក់ ដែលមានអ្នកទទួល សិទ្ធិមេធាវី កគស ចុះថ្ងៃទី២៨-៧-១៩៨៩ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ទាស់គតិច្បាប់ ។

៣- ទទួលស្គាល់មេធាវី ...............ដែលជាអ្នកទទួលសិទ្ធិឱ្យដើមចោទឈ្មោះ...............តាមលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៨-០៥-១៩៩៨ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលស្គាល់មេធាវី កែវ គឹមសាន្ត ដែលជាអ្នកទទួលសិទ្ធិពីចុងចម្លើយឈ្មោះថងសិទ្ធិ - លីឡាប្រាក់ថាក់ តាមលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២៤-០៦-១៩៩៨ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥- ឱ្យមោឃៈភាពកិច្ចសន្យាធ្វើសហការអាជីវកម្ម និងគ្រប់គ្រងរវាងក្រុមហ៊ុនពិភពពាណិជ្ជ ថងសិទ្ធិ លីឡាប្រាក់ថាក់ និង..............ចុះថ្ងៃទី០៨-០៦-១៩៩៧ ចោលចាប់ពីពេលនេះតទៅ ។

៦- បង្គាប់ឱ្យចុងចម្លើយឈ្មោះថងសិទ្ធិ លីឡាប្រាក់ថាក់ ដែលមានតំណាង និងជាមេធាវី ឈ្មោះ ..............សងប្រាក់ចំនួន៩៧០០៧$ (ប្រាំបួនម៉ឺនប្រាំពីរពាន់ ប្រាំពីរដូដុល្លាអាមេរិក)ប្រាក់រៀលចំនួន ១.៦៧៣០០០រៀល ( មួយរយហុកសិបប្រាំពីរម៉ឺនបីពាន់រៀល) ការប្រាក់ចំនួន៥% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី០៨-៦-១៩៩៧ នៃចំនួនប្រាក់ដើមទាំងអស់រហូតដល់ថ្ងៃសងគ្រប់ចំនួន និងសងជំងឺចិត្ត ចំនួន ៤០.០០០$ (បួនម៉ឺនដុល្លាអាមេរិក) ទៅឱ្យដើមចោទឈ្មោះវេសអវិញ ចាប់តាំងពីសាលក្រមចូលជាស្ថាពរ ។

បើឈ្មោះនេះ គ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិ ដែលមាននៅក្នុងដីកាសម្រេចតាម ពាក្យសុំលេខ០៣ (ឃ) ចុះថ្ងៃទី២៨-៥-១៩៩៨ លក់ឡាយឡុងធានាសំណង បើរឹងទទឹងត្រូវដាក់គុក បង្ខំដល់រូបកាយចំនួន៨ខែ តាមមាត្រា១៣៣ នៃច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៧- រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០រៀល រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ចំនួន២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ សរុប៧០០០៛ ពីចុងចម្លើយឈ្មោះថងសិទ្ធិ លីឡាប្រាក់ថាក់ មានតំណាងឈ្មោះកែវ គឹមសាន្ត បានបង់ទុករួចជាស្រេច ។

៨-បង្គាប់ឲ្យ ថងសិទ្ធិលីឡាប្រាក់ថាក់ ដែលមានតំណាងឈ្មោះ..............បង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥,០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួចជាស្រេច ។

កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយសងប្រាក់៧០០០៛ នេះទៅឱ្យដើមចោទីវិញ។

បង្គាប់ឲ្យឈ្មោះថងសិទ្ធិ លីឡាប្រាក់ថាក់ ដែលមានតំណាងឈ្មោះ..............បង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់ដើមចំនួន៩៧០០៧$ ប្រាក់រៀលចំនួន១.៦៣៧០០០រៀល និងការប្រាក់ ៥% ក្នុងមួយឆ្នាំព្រមទាំងជំងឺចិត្តចំនួន ៤០០០០$ ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋចំនួន៨០% និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៩- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគីសម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ២ ខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ១៥(ឃ) ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩ របស់មេធាវី លោកស្រីកគស ប្តឹងមិនសុខចិត្តនឹង សាលក្រមលេខ១២(ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៨៩ របស់តុលាការក្រុងភ្នំពេញ លើត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ១០(ឈ) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខមេធាវី តំណាងឱ្យដើមចោទលោកជចធរ កំបាំងមុខមេធាវីតំណាង ឱ្យចុងចម្លើយលោកស្រី...........ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-១០-៩៩ របស់ឈ្មោះ............ជាមេធាវី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២(ឃ) ចុះថ្ងៃទី២៣-០៩-៩៩ របស់តុលាការក្រុងភ្នំពេញទុកជាបានការ ។

៣- សម្រេចកាត់យកប្រាក់ប្រដាប់ក្តីចំនួន១៣០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០ រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥០០០រៀល និងចំណាយលើអាជ្ញាធរតុលាការចំនួន៥០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤-០៨-២០០០ ចំពោះមុខមេធាវីតំណាងឱ្យដើមចោទលោកជចធរ កំបាំងមុខមេធាវីតំណាងឱ្យចុងចម្លើយលោកស្រីកគស។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៩៧ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោកថងសិទ្ធិ លីឡាប្រាក់ថាក់ ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណីលេខ១០(ឈ) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៩(ឈ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខមេធាវីតំណាងឱ្យដើមចោទលោកជចធរ និងមេធាវីតំណាងឱ្យ ចុងចម្លើយអ្នកស្រីកគស ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងទាស់របស់មេធាវីកគស ចុះថ្ងៃទី១៦-១១-២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ១០(ឈ) ចុះថ្ងៃទី២៤-០៨-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងឱ្យដើមចោទ លោកជចធរ និងមេធាវីតំណាងឱ្យចុងចម្លើយ អ្នកស្រីកគស ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០០ របស់លោកស្រី............ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤៩(ឈ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី១៤-០៥-២០០១ របស់លោកស្រីកគស

បានឃើញសារណាតប ចុះថ្ងៃទី២៨-០៦-២០០១ របស់លោកវសអ

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថាៈ

សាលដីកាវដ្តប្បវេណីលេខ៤៩(ឈ) ចុះថ្ងៃទី២៨-១១-២០០០ របស់សាលាឧទ្ធរណ៍ ដែលបាន សម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេច ។

ក្រឡាបញ្ជីអានសារណារបស់លោកថងសិទ្ធិ លីឡាប្រាក់ថាក់

ក្រឡាបញ្ជីអានសារណារបស់លោក...............

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោកស្រី កគស បញ្ជាក់ថាៈ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ១៩៩៧ ក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា តំណាងដោយលោកថងសិទ្ធិ លីឡាប្រាក់ថាក់ បានព្រមព្រៀង ជាមួយលោក...............ចុះកិច្ចសន្យាធ្វើសហការ អាជីវកម និងគ្រប់គ្រងក្រោយកិច្ចសន្យានោះរួចមក ។ លុះថ្ងៃទី១១-១២-៩៧ ស្រាប់តែក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ចេញប្រកាសដកហូតទីតាំងពីភាគី កូនក្តីនាងខ្ញុំវិញ ហើយនៅថ្ងៃទី១៨-៥- ៩៨ ឈ្មោះ...............បែរជាមកប្តឹងភាគីកូនក្តីនាងខ្ញុំ ដោយពុំ គោរពកិច្ចសន្យា ព្រោះតាមកិច្ចសន្យា ចុះថ្ងៃទី៨-៦-៩៧ ត្រង់ចំណុចទី១,៤,៦ បានបញ្ជាក់យ៉ាងច្បាស់ ហើយថា ទោះបើជារដ្ឋាភិបាលសម្រេច ដកហូតសិទ្ធិគ្រប់គ្រងរោងចក្រ ដោយប្រការនោះក៏ដោយ ក៏មិនផ្ត ល់សិទ្ធិឲ្យភាគី(ខ) ទាមទារការខាតបង់អ្វីពីភាគី(ក) ឡើយ ។ ដូច្នេះបើមានការខាតបង់ដោយប្រការ ណាមួយ ក្រោយពីចុះកិច្ចសន្យាគឺគូភាគី ត្រូវទទួលខុសត្រូវរួមគ្នាពុំមែន ត្រូវឱ្យភាគីម្ខាងប្តឹងទាមទារពីភាគី ម្ខាងទៀតនោះទេ ។

ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចបដិសេធសាលដីកាលេខ១០(ឈ) ចុះថ្ងៃទី២៤-០៨-២០០០ របស់សាលាឧទ្ធរណ៍ចោលទាំងស្រុង ។ បដិសេធដីកាសម្រេចតាមពាក្យសុំលេខ០៣(យ) ចុះ ថ្ងៃទី២៨-០៥-១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាមោឃៈត្រង់ចំណុចឃាត់ផ្ទះលេខ៣១ និង៣៣ វិ ថីសម្តេចចក្រីប៉ុន សង្កាត់បឹងរាំង ខណ្ឌដូនពេញ ហើយប្រគល់ផ្ទះលេខ៣១ និង៣៣ ទៅឱ្យឈ្មោះសដវ វិញ ។

បានស្តាប់សចក្តីសន្និដ្ឋានរបស់មេធាវីលោក...............បញ្ជាក់ថា : នៅថ្ងៃទី៨-៦-៩៧ កូនក្តីរបស់ ខ្ញុំលោកវ៉ាន់ស៊ូអៀង និងលោកថងសិទ្ធិ លីឡាប្រាក់ថាក់ តំណាងក្រុមហ៊ុនពិភពពាណិជ្ជបានព្រមព្រៀង គ្នាចុះកិច្ចសន្យាសហការអាជីវកម្ម ដែលជាកិច្ចសន្យាជួលទីតាំង ពីក្រុមហ៊ុនពិភពពាណិជ្ជមានរយៈពេល កំណត់ច្បាស់លាស់៥ឆ្នាំ និងកំរៃ ៦០០០ដុល្លា ក្នុងមួយឆ្នាំ ដូចមាន កំណត់ក្នុងមាត្រា៨ និង៤ នៃកិច្ច សន្យា ។ ចាប់តាំងពីថ្ងៃទី៨-៦-៩៧ ដែលបានព្រមព្រៀងគ្នាមកបានអនុវត្តកាតព្វកិច្ច ដូចជាៈ

- ប្រគល់ប្រាក់កក់គ្រប់ចំនួន៦០០០០ដុល្លា គឺ នៅថ្ងៃទី៨-៦-៩៧ចំនួន៣០០០០ដុល្លា និងនៅថ្ងៃ ទី២៥-០៧-៩៧ ចំនួន៣០០០០ដុល្លា ។

-ប្រគល់ប្រាក់ថ្លៃជួលដុលពីមុនចំនួន១២៥០០ដុល្លា គឺនៅថ្ងៃទី២២-១០-៩៧ ចំនួន៨០០០ ដុល្លា និងនៅថ្ងៃទី០៨-១២-៩៧ ចំនួន៤៥០០ដុល្លា ទៅឲ្យក្រុមហ៊ុនពិភពពាណិជ្ជ ។

-បានចំណាយប្រាក់ជួសជុលកែលំអរោងចក្រឡើងវិញ អស់ចំនួន ១៩៥០៧ដុល្លា ។

-បង់ប្រាក់ឈ្នួលប្រចាំខែដំបូង៥០០០ដុល្លា។

-បង់ថ្លៃទឹកអគ្គីសនី១៦៧៣០០០រៀល ។ សរុបចំណាយទាំងអស់៩៧០០៧ដុល្លា និង ១៦៧៣០០០ រៀល ។

សូមក្រុមប្រឹក្សាជំនុំជំរះ តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៨(ឈ) ចុះថ្ងៃទី២៨១១-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី២២-០១-២០០១ របស់អ្នកស្រីកគស មេធាវីរបស់ចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី។

យល់ឃើញថា ការដែលអ្នកស្រីកគស លើកឡើងក្នុងសារណា ចុះថ្ងៃទី១៤-៥-២០០១ ថា តាមប្រការ១៤-៦ នៃកិច្ចសន្យាសហការអាជីវកម្ម និងគ្រប់គ្រង ចុះថ្ងៃទី៨-៦-៩៧ បញ្ជាក់ថាៈ ទោបីរដ្ឋាភិបាលសម្រេចដកហូតសិទ្ធិគ្រប់គ្រងរោងចក្រដោយប្រការនោះក៏ដោយ ក៏មិនផ្តល់ សិទ្ធិឱ្យភាគី(ខ) ទាមទារការខាតបង់អ្វីពីភាគី(ក)បានឡើយ ហើយការខាតបង់ណាមួយក្រោយ ពីចុះកិច្ចសន្យា គួភាគីត្រូវទទួលខុសត្រូវរួមគ្នា ពុំមែនឱ្យភាគីម្ខាងប្តឹងទាមទារពីភាគីម្ខាងទៀតនោះទេ គឺជាការពុំត្រឹមត្រូវទេ ពីប្រព្រោះចុងចម្លើយបានជំពាក់ប្រាក់ថ្លៃឈ្នួលរោងចក្ររបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលតាំងពីមុនចុះកិច្ចសន្យាថ្ងៃទី៨-៦-៩៧ ដោយដើមចោទពុំបានដឹង ដែលជាមូលហេតុធ្វើឱ្យរដ្ឋសំរេចដកហូតយកទីតាំងនេះវិញ ។ ដូច្នេះដើមហេទពុំអាចទទួលខុសត្រូវលើការខាតបង់តាមប្រការ១៤,៦ នៃកិច្ចសន្យា សហការអាជីវកម្ម និង គ្រប់គ្រងបានទេ ពីព្រោះការដកហូតទីតំណែងនេះ មិនមែនបណ្តាលមកពីការកកំរ៉ែ នៃ ការជួលអចលនវត្ថុទេ ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមសម្រេចដាក់គុកបង្ខំលើរូបកាយលោកថងសិទ្ធិលីឡាប្រាក់ថាក់ ដែលជានីតិបុគ្គលនោះ ជាការពុំត្រឹមត្រូវទេ ប៉ុន្តែដោយរឿងនេះ ជារឿងអង្គច្បាប់សុទ្ធសាធ ដូច្នេះ តុលាការកំពូល គប្បីសម្រេច ទុកជាមោឃៈ ដោយឥតបង្វិល ។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយ ក៏ដូចជាសារណារបស់ចុងចម្លើយដែរ ដែលលើកឡើងថា ការឱ្យជម្ងឺចិត្ត៤ម៉ឺនដុល្លាអាមេរិក មានចំនួនច្រើនហួសនោះ តុលាការកំពូល ដែលជំនុំជំរះ ពេលនេះ តែលើអង្គច្បាប់ពុំមានសមត្ថកិច្ចសម្រេចបានឡើយ ពីព្រោះជាសមត្ថកិច្ចរបស់តុលាការអង្គសេចក្តី ។

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី១២-០៦-២០០១ របស់លោកលឹម ច័ន្ទប៉ុនកែវ ជាមេធាវីរបស់អ្នកស្រីសដវដែលសុំចូលជាតតិយជននោះ តុលាការកំពូលពុំមានសមត្ថកិច្ចជំនុំជំរះបាន ឡើយ ពីព្រោះតុលាការកំពូលជំនុំជំរះលើកទី១ តែលើអង្គច្បាប់ មិនពិនិត្យលើអង្គហេតុថ្មីទេ ។

- យល់ឃើញថា គូភាគី បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះ មានតែមេធាវី នៃគូភាគី ដែលបានមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៩(ឈ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយលើកលែងតែចំណុចដាក់គុកបង្ខំលើរូបកាយ ។

## ហេតុដូច្នេះ

## ចច្ឆ័យសេចក្តីកំបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០១ របស់អ្នកស្រីកគស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹង គតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៨(ឈ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចដាក់គុកបង្ខំលើរូបកាយ ដែលត្រូវទុកជាមោឃៈដោយឥតបង្វិល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក...............បានបង់ជួសរួចហើយគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវ ឱ្យចុងចម្លើយសងប្រាក់១៩០០០រៀល នេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ តាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ។